## កូនសៀវភៅស្តីពីអភិក្រមផ្អែកលើសិទ្ធិមនុស្សសំរាប់ការគ្រប់គ្រងពន្ធនាគារ៖ លិខិតុបករណ៍យោងសំរាប់ការបណ្តុះបណ្តាលដល់បុគ្គលិកពន្ធនាគារ

ក្នុងក្របខ័ណ្ឌនៃកម្មវិធីរបស់ខ្លួន គាំទ្រដល់កំណែទម្រង់ពន្ធនាគារនៅកម្ពុជា ការិយាល័យ OHCHR បានផលិតសំណៅជាភាសាខ្មែរនៃ*កូនសៀវភៅស្តីពីអភិក្រមផ្អែកលើសិទ្ធិមនុស្សសំរាប់ការគ្រប់គ្រងពន្ធនាគារ* ដែលបានបោះពុម្ពផ្សាយដោយមជ្ឈមណ្ឌលអន្តរជាតិ(ICPS ) ដែលមានមូលដ្ឋាននៅទីក្រុងឡុងដុងសំរាប់ការសិក្សាអំពីពន្ធនាគារ។ សំណៅជាភាសាខ្មែរនៃកូនសៀវភៅនេះ បានផ្តល់ដល់ក្រុមចម្រុះនៃគ្រូឧបទ្ទេសបុគ្គលិកពន្ធនាគារមកពីអគ្គនាយកដ្ឋានពន្ធនាគារ(GDP) និងបណ្ឌិត្យសភានគរបាលកម្ពុជា(PAC)។ ក្នុងខែកញ្ញា ឆ្នាំ២០១៣ ការិយាល័យ OHCHR - ប្រចាំកម្ពុជា បានផ្តល់កូន សៀវភៅនេះចំនួន១៥០ ក្បាលដល់លោកឧត្តមសេនីយទោ សុន វុទ្ធី នាយកនៃមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈអនុរក្សពន្ធនាគារ បណ្ឌិត្យសភានគរបាលកម្ពុជា ក្រសួងមហាផ្ទៃ សំរាប់ចែកចាយដល់សិក្ខាកាមបុគ្គលិកពន្ធនាគារ។ កូនសៀវភៅនេះចងក្រងឡើងក្នុងគោលបំណងសំរាប់ប្រើប្រាស់ជាលិខិតុបករណ៍យោងសំរាប់ការបង្កើតកម្មវិធីសិក្សាសំរាប់បុគ្គលិកពន្ធនាគារទើបបានជ្រើសរើសថ្មី ដើម្បីពង្រីកការយល់ដឹងរបស់ពួកគេ អំពីបទដ្ឋាន និងគោលការណ៍ស្តីពីការគ្រប់គ្រងល្អលើពន្ធនាគារ ក៏ដូចជា ដើម្បីកសាងជំនាញចាំបាច់ ដើម្បីប្រែក្លាយចំណេះដឹងទាំងនេះឲ្យទៅជាឥរិយាបទនៃការអនុវត្តជាក់ស្តែង។

End.